**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០០៣/០១/២០០៧ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧

**សូមជម្រាបជូន**

**លោកជំទាវ ប្រធានគណៈកម្មការសិទ្ធិមនុស្ស**

**ទទួលពាក្យបណ្ដឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា**

**កម្មវត្ថុ** : អំពីសំណើសុំពិនិត្យធម្មនុញ្ញភាពផ្លូវច្បាប់រវាងខ្លឹមសារលិខិតលេខ ៥៨៨ ស.ជ.ណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និង សាលដីកាស្ថាពររបស់តុលាការកំពូល

**យោង** : លិខិតរបស់លោកជំទាវលេខ ៣៤៧ រស.គ១ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០០៧ ផ្ញើមកក្រុម-ប្រឹក្សាធម្មនុញ្ញ តាមរយៈសម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកជំទាវប្រធានគណៈកម្មការថា ក្រុម-ប្រឹក្សាធម្មនុញ្ញបានទទួលសំណើរបស់លោកជំទាវ និង បានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧ ព្រមទាំងបានសម្រេចដូចតទៅ :

១-សំណើសុំពិនិត្យធម្មនុញ្ញភាពផ្លូវច្បាប់រវាងខ្លឹមសារលិខិតលេខ ៥៨៨ ស.ជ.ណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និង សាលដីកាស្ថាពររបស់តុលាការកំពូល មិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

២-បុគ្គលស្នើសុំពិនិត្យធម្មនុញ្ញភាពពុំមានគុណវុឌ្ឍិស្របតាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញទេ

៣-រឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ ។

សូមលោកជំទាវប្រធានគណៈកម្មការទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**